**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ:.....០១ សរ.ជណស

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០...

# សារាចរណែនាំ

## ស្តីពី

## វិធានការការពារ និងសង្គ្រោះស្ថានីយបុរាណវិទ្យា

បេតិកភណ្ឌវប្បធម៌ទាំងរូបីនិងអរូបី ជាកេរតំណែលដែលឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃអារ្យធម៌ពីអតីតកាលនៃជាតិសាសន៍និមួយៗ។ កេរតំណែលទាំងនោះ ជាភស្តុតាងបង្ហាញពីភាពថ្កុំថ្កើងរុងរឿងផ្នែកសិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ សាសនា ជីវភាពរស់នៅប្រចាំថ្ងៃរបស់សង្គមមនុស្សពីជំនាន់មួយទៅជំនាន់មួយ ។ មិនតែប៉ុណ្ណោះបេតិកភណ្ឌវប្បធម៌ទាំងនៅលើដី ក្រោមដី ក្រោមទឹក គឺជាឃ្លាំងឯកសារយ៉ាងសម្បូរបែបសម្រាប់ការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា បាសាណីភូតវិទ្យា ធម្មជាតិវិទ្យា បរិស្ថាន ជីវវិទ្យា ប្រវត្តិសាស្ត្រ ភូគព្ភសាស្ត្រ នរវិទ្យា ជាតិពន្ធុវិទ្យា និងវិទ្យាសាស្ត្រដទៃទៀតសម្រាប់មនុស្សគ្រប់ជំនាន់ ។

បុព្វបុរសកម្ពុជាបានបន្សល់ទុកកេរ្តិ៍មរតកវប្បធម៌មិនអាចកាត់ថ្លៃបាន នៅរាយប៉ាយពេញផ្ទៃប្រទេសដែលពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចចូលរួមថែរក្សាការពារឱ្យបានគង់វង្សជានិរន្តរ៍ ។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននិងកំពុងពុះពារគ្រប់ឧបសគ្គដឹកនាំអនុវត្ត គោលនយោបាយអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ទទួលបានលទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់ល្បីរន្ទឺពាសពេញពិភពលោក ។ ព្រមជាមួយនេះក៏កើតឡើងនូវបាតុភាពអសកម្មខ្លះដែលបាននិងកំពុងធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សម្បត្តិវប្បធម៌ជាតិ ទាំងនៅលើដី ក្រោមដី ក្រោមទឹក...។ល។ បណ្តាលមកពីការជីក-លុប-ឈូសឆាយ សាងសង់នៅតាមស្ថានីយបុរាណវិទ្យា ដោយគ្មានការសិក្សាស្រាវជ្រាវកត់ត្រាទិន្នន័យប្រវត្តិសាស្ត្រ ធ្វើឱ្យបាត់បង់បេតិកភណ្ឌវប្បធម៌ជាតិគួរឱ្យកត់សម្គាល់ ។

ដើម្បីសង្គ្រោះស្ថានីយបុរាណពីផលប៉ះពាល់ជាអវិជ្ជមាន និងបញ្ចៀសគ្រោះមហន្តរាយដែលអាចកើតឡើងជាថ្មីទៀត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលជាស្ថាប័នមានសមត្ថកិច្ចស្នូលក្នុងកិច្ចការថែរក្សាបេតិកភណ្ឌវប្បធម៌ ស្របតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងអនុក្រឹត្យលេខ៩៨អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ សម្រេចដាក់ចេញនូវវិធានការគ្រប់គ្រងចាំបាច់មួយចំនួនដូចតទៅ:

១-នីតិបុគ្គល ឬរូបវន្តបុគ្គលដែលគ្រោងជីក ឈូស ឆាយ ពង្រាប ចាក់ដី ឬសាងសង់ ក្នុងតំបន់ដែលក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានប្រកាសថា ជាដែនបុរាណវិទ្យា ឬសង្ស័យថាជាដែនបុរាណវិទ្យា ត្រូវធ្វើទំនាក់ទំនងមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីសុំក្រុមឯកទេសបុរាណវិទ្យាទៅពិនិត្យស្រាវជ្រាវ រិះរកវិធីបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថានីយបុរាណវិទ្យា ក្នុងករណីមិនអាចបញ្ចៀសបានត្រូវធ្វើកំណាយសង្គ្រោះ ។



ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ : ស្ថិតនៅតាមបណ្តោយមហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

២-អ្នកទទួលខុសត្រូវការដ្ឋានត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់ក្រុមឯកទេស ដែលមានបេសកកម្មក្នុងទីតាំងការដ្ឋានរបស់ខ្លួន ដើម្បីសហការិរកវិធីបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថានីយបុរាណវិទ្យា ឬធ្វើកំណាយសង្គ្រោះ ។

៣-កំណាយសង្គ្រោះជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែភូមិសាស្ត្រដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា និងអាជ្ញាធរជាតិព្រះវិហារ ។

៤-ចំពោះមុខនេះ ចំណាយសមស្របសម្រាប់ប្រតិបត្តិការរបស់ក្រុមឯកទេសធ្វើកំណាយសង្គ្រោះ ជាបន្ទុករបស់អ្នកគ្រប់គ្រងទីតាំងដែលត្រូវធ្វើកំណាយ ។

៥-វត្ថុសិល្បៈដែលបានប្រទះឃើញ ក្នុងប្រតិបត្តិការស្រាវជ្រាវបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថានីយបុរាណវិទ្យា ឬកំណាយសង្គ្រោះ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈ ដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាអ្នកគ្រប់គ្រង ។

៦-ក្នុងពេលដំណើរការការងារតាមគ្រប់ការដ្ឋាន ប្រសិនបើជួបប្រទះសម្បត្តិវប្បធម៌ ដូចជាប្រាសាទបែកបាក់ វត្ថុបុរាណសំណល់ផ្ទះសម្បែង វត្ថុប្រើប្រាស់ពីសម័យបុរាណ សិលាចារឹក ឬសម្បត្តិវប្បធម៌ដែលមានប្រយោជន៍ដល់ការសិក្សាខាងបុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាណាសីភូតវិទ្យា ឬសាខានៃវិទ្យាសាស្ត្រផ្សេងទៀត ដែលសិក្សាអំពីអតីតកាល ឬទាក់ទងដល់មនុស្សសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋាននោះត្រូវផ្អាកសកម្មភាពត្រង់ទីតាំងដែលប្រទះឃើញនោះជាបន្ទាន់ រួចប្តឹងដំណឹងទៅភ្នាក់ងារនគរបាលក្នុងតំបន់ ឬភ្នាក់ងាររបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលនៅជិតបំផុតដើម្បីពិនិត្យនិងចាត់វិធានការសង្គ្រោះសម្បត្តិវប្បធម៌នោះ ។

៧- រាល់សកម្មភាពជីក ឈូស ឆាយ ចាក់ដីបំពេញលើទំនាប សាងសង់ ក្នុងដែនបុរាណវិទ្យាដោយពុំបានសិក្សាស្រាវជ្រាវបញ្ចៀសផលប៉ះពាល់ស្ថានីយបុរាណវិទ្យា ឬធ្វើកំណាយសង្គ្រោះ ចាត់ទុកជាអំពើល្មើសនឹងច្បាប់ស្តីពីការការពារបេតិកភណ្ឌ និងអនុក្រឹត្យលេខ៩៨ អនក្រ.បក. ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ។

៨-ទទួលបានសារាចរណែនាំនេះ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ត្រូវរាយការណ៍ជូនឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ដើម្បីសុំគោលការណ៍ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់អាជ្ញាធរពាក់ព័ន្ធ មន្ទីរជំនាញនានា និងផ្នែកឯកជន សំដៅរួមគ្នាអនុវត្តវិធានការការពារ និងសង្គ្រោះស្ថានីយបុរាណវិទ្យាឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្រុមហ៊ុន សហគ្រាសរដ្ឋ ឯកជន នីតិបុគ្គលឬរូបវន្តបុគ្គល ដែលមានការពាក់ព័ន្ធពិតជាចូលរួមសហការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ឱ្យនៅគង់វង្សយូរអង្វែងតទៅ ។

សារាចរណែនាំនេះមានប្រសិទ្ធភាពចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
  "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាបនិងជួយសហការ"
- គ្រប់អង្គភាពចំណុះក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
  "ដើម្បីជ្រាបនិងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ